ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ៥៤០.៧៥សហវ.......

រាជធានីភ្នំពេញ ថ្ងៃទី២៣ ខែ សីហា ឆ្នាំ ២០១៧

**សូមគោរពជូន**
**សម្តេចអគ្គមហាពញាចក្រី ហេង សំរិន**
**ប្រធានរដ្ឋសភា**

**កម្មវត្ថុ៖** របាយការណ៍ស្តីពីលទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ និងលទ្ធផលប៉ាន់ស្មាននៃការអនុវត្តថវិកាឆ្នាំ ២០១៧។

**យោង៖** - មាត្រា៣៧នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលប្រកាសឱ្យប្រើដោយព្រះរាជក្រម លេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨។
- ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុ និងយោងខាងលើ ខ្ញុំសូមការអនុញ្ញាតគោរពជម្រាបជូន **សម្តេចអគ្គមហាពញាចក្រី** មេត្តាជ្រាបដ៏ខ្ពង់ខ្ពស់ថា អនុលោមតាមមាត្រា ៣៧ នៃច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សូមគោរពរាយការណ៍ជូនរដ្ឋសភាជ្រាប អំពីស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងលទ្ធផលនៃការអនុវត្តថវិកាក្នុងឆមាសទី១ និងលទ្ធផលប៉ាន់ស្មាននៃការអនុវត្តថវិការហូតដល់ដំណាច់ឆ្នាំ ២០១៧ ក្នុងបរិការណ៍នៃការអនុវត្តការកែទម្រង់ស៊ីជម្រៅរបស់រាជរដ្ឋាភិបាលនីតិកាលទី ៥ នៃរដ្ឋសភា ដែលមានខ្លឹមសារដូចតទៅ៖

## ១. គោលនយោបាយ និងក្របខណ្ឌនៃច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ដែលត្រូវបានដាក់ចេញ

### ក-អាទិភាពគោលនយោបាយដែលត្រូវបានដាក់ចេញ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ (ច្បាប់ថវិកាឆ្នាំ ២០១៧) ត្រូវបានរៀបចំនៅក្នុងទិសដៅកែទម្រង់ដ៏ជាក់លាក់មួយ និងដើម្បីជានាចលនការនៃការកែទម្រង់ ព្រមទាំងតម្រង់ និងតម្រឹមគោលដៅនៃការកែទម្រង់ ស្របទៅតាមបំណងប្រាថ្នារបស់ប្រជាជនកម្ពុជា ក៏ដូចជាសម្រេចឱ្យបាននូវគោលដៅជា**យុទ្ធសាស្ត្រ ៤** ដូចមានចែងក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី៣** ដើម្បី **កំណើន ការងារ សមធម៌ និងប្រសិទ្ធភាពនៅកម្ពុជា** ដែលជារបៀបវារៈគោលនយោបាយសង្គម-សេដ្ឋកិច្ច នៃកម្មវិធីនយោបាយរបស់**រាជរដ្ឋាភិបាលនីតិកាលទី៥ នៃរដ្ឋសភា** គឺ៖

*ទី១.* ធានាឱ្យបាននូវកំណើនសេដ្ឋកិច្ចក្នុងអត្រាមធ្យមប្រចាំឆ្នាំប្រមាណ ៧% ប្រកបដោយចីរភាព និងបរិយាប័ន្ន សមធម៌ និងធន់នឹងវិបត្តិ

*ទី២.* បង្កើតការងារឱ្យបានកាន់តែច្រើនឡើងជូនប្រជាជន ពិសេសសម្រាប់ស្រទាប់យុវជន តាមរយៈការវិនិយោគ

*ទី៣.* សម្រេចឱ្យបាននូវគោលដៅនៃការកាត់បន្ថយភាពក្រីក្រ ក្នុងអត្រាជាង ១% ក្នុងមួយឆ្នាំ ក៏ដូចគោលដៅអភិវឌ្ឍន៍ផ្សេងទៀត ទន្ទឹមនឹងការផ្តោតអាទិភាពកាន់តែខ្លាំងឡើងទៅលើការអភិវឌ្ឍធនធានមនុស្ស និងការពង្រឹងការគ្រប់គ្រងបរិស្ថាននិងធនធានធម្មជាតិ

*ទី៤.* បន្តពង្រឹងសមត្ថភាព និងអភិបាលកិច្ចនៃស្ថាប័នរដ្ឋ សំដៅបម្រើប្រជាជនឱ្យកាន់តែប្រសើរឡើង។

ដើម្បីគោលដៅខាងលើ ថវិកាឆ្នាំ ២០១៧ ក៏បន្តផ្តោតការយកចិត្តទុកដាក់លើ **វិស័យអាទិភាព ៤** ដែលមានដូចខាងក្រោម ៖

*ទី១.* ការអភិវឌ្ឍធនធានមនុស្ស និងការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ ដោយផ្តោតជាពិសេសលើយុវជន

*ទី២.* ការបន្តវិនិយោគលើវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវន្ត និងការកែលម្អថែមទៀតនូវកិច្ចសម្រួលពាណិជ្ជកម្ម ដើម្បីបង្កើនភាពទាក់ទាញ និងភាពប្រកួតប្រជែងរបស់សេដ្ឋកិច្ចកម្ពុជា

*ទី៣.* ការបន្តអភិវឌ្ឍវិស័យកសិកម្ម ក្នុងគោលដៅជំរុញកំណើនសេដ្ឋកិច្ច និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាជន ព្រមទាំងជំរុញការអភិវឌ្ឍសេដ្ឋកិច្ចជនបទ តាមរយៈការបង្កើនផលិតភាពទំនើបកម្មកសិកម្ម ឧស្សាហូបនីយកម្ម និងការលើកកម្ពស់ពាណិជ្ជូបនីយកម្ម

*ទី៤.* ការពង្រឹងអភិបាលកិច្ច និងសមត្ថភាពនៃស្ថាប័នរដ្ឋ សំដៅបង្កើនប្រសិទ្ធភាព និងគុណភាពនៃសេវាសាធារណៈ ភាពប្រកួតប្រជែងរបស់កម្ពុជា និងការកែលម្អបរិយាកាសវិនិយោគ ។

ស្របតាមអាទិភាពនេះ ថវិកាឆ្នាំ ២០១៧ បានបង្កើនចំណាយលើវិស័យអប់រំ, ការបណ្តុះបណ្តាលបច្ចេកទេសវិជ្ជាជីវៈ, វិស័យសុខាភិបាល, វិស័យកសិកម្ម, ហេដ្ឋារចនាសម្ព័ន្ធ និងការតភ្ជាប់ដែលជាមូលដ្ឋានគ្រឹះនៃការជំរុញកំណើន និងការប្រកួតប្រជែងរបស់កម្ពុជា។ ទន្ទឹមនេះដែរ **ការដំឡើងបៀវត្សមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទ គឺនៅតែជាគោលនយោបាយអាទិភាពនៃថវិកាឆ្នាំ ២០១៧** ដោយបានបង្កើនចំណាយបន្ទុកបុគ្គលិកឱ្យឡើងរហូតដល់ ៥១,៧% នៃចំណាយចរន្តថវិការដ្ឋ ឬស្មើនឹង ៨,០១% នៃ ផសស។

## ខ-ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចដែលត្រូវបានដាក់ចេញ

ច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ត្រូវបានរៀបចំឡើងដោយឈរលើមូលដ្ឋាននៃការកំណត់ក្របខណ្ឌម៉ាក្រូសេដ្ឋកិច្ចសម្រាប់ឆ្នាំ ២០១៧ ដែលមានសូចនាករសំខាន់ៗ ដូចខាងក្រោម៖

• កំណើនសេដ្ឋកិច្ចឆ្នាំ ២០១៧ នឹងនៅតែបន្តរឹងមាំក្នុងរង្វង់ ៧,០% ដែលធ្វើឱ្យផលិតផលក្នុងស្រុកសរុប (ផសស) គិតជាទឹកប្រាក់តាមថ្លៃបច្ចុប្បន្នមានចំនួន ៨៩ ០៣២ ៥៨៦ លានរៀល សមមូលនឹងប្រមាណ ២១ ៩៨៣ លានដុល្លារអាមេរិក ហើយផសសសម្រាប់មនុស្សម្នាក់រំពឹងថានឹងឡើងដល់ ១ ៤២២ ដុល្លារអាមេរិក,

•អតិផរណានឹងត្រូវបានរក្សាឱ្យស្ថិតក្នុងរង្វង់ ៣,៧%,

•អត្រាប្តូរប្រាក់រៀល-ដុល្លារអាមេរិកនឹងត្រូវបានរក្សាឱ្យស្ថិតក្នុងរង្វង់ ៤ ០៥០ រៀល ក្នុង ១ដុល្លារអាមេរិក,

•ឱនភាពគណនីចរន្តនៃជញ្ជីងទូទាត់ក្រៅប្រទេស ត្រូវបានប៉ាន់ប្រមាណថានឹងថយចុះពី-៩,១% នៃ ផសស ក្នុងឆ្នាំ ២០១៦ ទៅ -៨,៥% នៃ ផសស ក្នុងឆ្នាំ ២០១៧ ខណៈដែលឱនភាពពាណិជ្ជកម្មត្រូវបានប៉ាន់ស្មានថានឹងថយចុះពី -១៧,៩% នៃ ផសស ក្នុងឆ្នាំ ២០១៦ មកនៅត្រឹម -១៦,៨% ក្នុងឆ្នាំ ២០១៧។

## គ-ក្របខណ្ឌគោលនយោបាយថវិកាឆ្នាំ ២០១៧ ដែលត្រូវបានដាក់ចេញ

ក្នុងគោលបំណងដើម្បីសម្រេចបានតាមគោលដៅខាងអាទិភាពគោលនយោបាយ និងគោលដៅខាងម៉ាក្រូសេដ្ឋកិច្ច ដូចបានគូសបញ្ជាក់ខាងលើ រាជរដ្ឋាភិបាលបានដាក់ចេញនូវក្របខណ្ឌថវិកាឆ្នាំ ២០១៧ ដូចខាងក្រោម៖

| **សូចនាករ** | **២០១៥** | **២០១៦** | | **២០១៧** | |
|---|---|---|---|---|---|
| | **អនុវត្ត** | **ច្បាប់** | **អនុវត្ត** | **ច្បាប់** | |
| ផសស (លានរៀល) | ៧៣ ៤២២ ៧០២ | ៨០ ៥៥៨ ៥៣២ | | ៨៩ ០៣២ ៥៨៦ (*) | ៨៩ ៥០៩ ៤២២ (**) |
| ចំណូលក្នុងប្រទេស (%ផសស) | ១៧,៣២% | ១៧,៨២% | ១៨,៧៦% | ១៨,៦៦% | ១៨,៥៧% |
| *- ចំណូលចរន្ត (%ផសស)* | ១៧,១៥% | *១៧,៦៦%* | *១៨,៦១%* | ១៨,៥០% | ១៨,៤០% |
| ចំណាយសរុបថវិកាជាតិ (%ផសស) | ២០,៤៨% | ២២,៧០% | ២២,០២% | ២៣,៧៦% | ២៣,៦៣% |
| *- ចំណាយចរន្ត (%ផសស)* | ១៣,០០% | *១៤,៦៨%* | *១៤,២៨%* | ១៥,៥០% | ១៥,៤២% |
| អតិរេកចរន្ត (%ផសស) | ៤,១៦% | ២,៩៨% | ៤,៣៣% | ៣,០០% | ២,៩៨% |
| ឱនភាពសរុប (%ផសស) | -៣,៥៦% | -៤,៨៧% | -៣,២៧% | -៥,០៩% | -៥,០៧% |

*សេចក្តីបញ្ជាក់៖*

*-(*) ផសស តាមថ្លៃបច្ចុប្បន្ន ដែលបានព្យាករណ៍នៅក្នុងឆ្នាំ ២០១៦ សម្រាប់ការរៀបចំច្បាប់ថវិកា ២០១៧*

*-(**) ផសស តាមថ្លៃបច្ចុប្បន្នថ្មី តាមការប៉ាន់ស្មាន នៅពាក់កណ្តាលឆ្នាំ ២០១៧*

តាម ផសស គិតជាទឹកប្រាក់តាមថ្លៃបច្ចុប្បន្នដែលបានព្យាករណ៍នៅក្នុងឆ្នាំ ២០១៦ សម្រាប់ការរៀបចំច្បាប់ថវិកាឆ្នាំ ២០១៧ ចំណូលក្នុងប្រទេសត្រូវបានគ្រោងចំនួន ១៦ ៦១៧ ៤២៨ លានរៀល ស្មើនឹង ១៨,៦៦% នៃ ផសស និងមានកំណើន ១៥,៧% ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុឆ្នាំ ២០១៦។ **ក្របខណ្ឌថវិកាឆ្នាំ ២០១៧ មានគោលដៅបង្កើនចំណូលចរន្តឱ្យបានស្មើនឹង ១៨,៥% នៃ ផសស ដែលមានកំណើនចំនួន ០,៧៩ ពិន្ទុភាគរយ ធៀបនឹងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៦** ពោលគឺគ្រោងសម្រេចបានលើសពីគោលដៅដែលបានដាក់ចេញនៅក្នុង **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ដែលបានកំណត់ថា រាជរដ្ឋាភិបាលត្រូវប្រមូលចំណូលចរន្តថវិការដ្ឋឱ្យបានកើនស្មើនឹង ០,៥០ ពិន្ទុភាគរយនៃ ផសស ជាប្រចាំឆ្នាំក្នុងរយៈពេលមធ្យម។

## ២. លទ្ធផលនៃការអនុវត្តច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ នៅក្នុងឆមាសទី ១

ផ្អែកតាមការវាយតម្លៃពាក់កណ្តាលឆ្នាំ ២០១៧, សកម្មភាពសេដ្ឋកិច្ចកម្ពុជានៅតែបន្តកំណើនរឹងមាំតាមការគ្រោងទុកនៅក្នុងរង្វង់ ៧,០% ដែលឆ្លុះបញ្ចាំងតាមរយៈការបន្តកំណើនរឹងមាំ និងមានស្ថេរភាពនៃវិស័យដែលជាជន្ទល់សេដ្ឋកិច្ច ដូចជា វិស័យសំណង់ កាត់ដេរ ទេសចរណ៍ និងកសិកម្ម ទោះបីកម្ពុជាបានជួបប្រឈមហានិភ័យ និងបញ្ហាប្រឈមមួយចំនួនទាំងក្នុង និងក្រៅប្រទេសក៏ដោយ។ ជាមួយនឹង ការបន្តអនុវត្តកម្មវិធីកែទម្រង់លើគ្រប់វិស័យ ក្នុងគោលដៅគាំទ្រកំណើន, ជំរុញការធ្វើពិពិធកម្មសេដ្ឋកិច្ច និងបង្កើនភាពប្រកួតប្រជែងរបស់កម្ពុជា រាជរដ្ឋាភិបាលបាននិងកំពុងគ្រប់គ្រងបានយ៉ាងល្អនូវហានិភ័យពាក់ព័ន្ធនឹងម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈការដាក់ចេញវិធានការមួយចំនួនដើម្បីបង្កើនសន្ទនីយភាព (Build Liquidity) និងទ្រនាប់មូលធន, ការបង្កើនប្រាក់បម្រុងកាតព្វកិច្ច, ការដាក់ចេញក្របខណ្ឌគ្រប់គ្រងវិបត្តិ និងការបន្តធ្វើបច្ចុប្បន្នភាពបទប្បញ្ញត្តិ និងការត្រួតពិនិត្យ ទាំងស្ថាប័នធនាគារនិងហិរញ្ញវត្ថុ និងទាំងស្ថាប័នមិនមែនធនាគារ។ លើសពីនេះ ការអនុវត្តគោលនយោបាយវិត្តារកម្មថវិកាត្រូវបានគិតគូរ ដើម្បីធានាថាការដំឡើងប្រាក់បៀវត្សមានសង្គតិភាពជាមួយចីរភាពថវិកា ហើយអាទិភាពចំណាយក៏ត្រូវបានផ្តោតលើការអភិវឌ្ឍន៍។

ចំពោះការអនុវត្តថវិកានៅឆមាសទី១នេះ ជារួម លទ្ធផលបានបង្ហាញថា ស្ថានភាពនៃការប្រមូលចំណូលនៅក្នុងឆមាសទី ១ នៅបន្តរឹងមាំ ដោយអនុវត្តបានល្អទាំងផ្នែកចំណូលចរន្ត និងចំណូលមូលធន ចំណែកការអនុវត្តចំណាយក៏បានប្រសើរជាងឆ្នាំ ២០១៦ បើគិតក្នុងរយៈពេលដូចគ្នា ក្នុងខណៈដែលប្រសិទ្ធភាពនៃការវិភាជថវិកា និងប្រសិទ្ធភាពកម្រិតប្រតិបត្តិការចំណាយត្រូវបានបន្តពង្រឹង។ លទ្ធផលល្អនៃការអនុវត្តចំណូលនេះ មិនត្រឹមតែអាចឆ្លើយតបបានទៅនឹងតម្រូវការចំណាយប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងបង្កើតបាននូវអតិរេកសាច់ប្រាក់បន្ថែមទៀត សម្រាប់បង្កើនប្រាក់បញ្ញើរបស់រាជរដ្ឋាភិបាលក្នុងការទប់ទល់នឹងវិបត្តិនានាជាយថាហេតុ។

### ក-ស្ថានភាពម៉ាក្រូសេដ្ឋកិច្ច

ក្នុងឆ្នាំ ២០១៦ កន្លងទៅនេះ សេដ្ឋកិច្ចកម្ពុជានៅរក្សាបានកំណើនរឹងមាំដូចទៅនឹងឆ្នាំមុនពោលគឺក្នុងអត្រាកំណើន ៧,០% ដែលបន្តគាំទ្រដោយការងើបឡើងវិញនៃវិស័យកសិកម្ម កំណើនរឹងមាំនៃវិស័យសំណង់ ទោះបីមានការថមថយបន្តិច និងកំណើនគួរឱ្យកត់សម្គាល់នៃវិស័យមិនមែនកាត់ដេរ។ ប្រការនេះបានធ្វើឱ្យ ផសស សម្រាប់មនុស្សម្នាក់កើនឡើងពី ១ ២១៥ ដុល្លារ នៅឆ្នាំ ២០១៥ ដល់ ១ ៣០២ ដុល្លារនៅឆ្នាំ ២០១៦។ កំណើននៃវិស័យកសិកម្មចាប់ផ្តើមងើបឡើងវិញពី ០,២% ក្នុងឆ្នាំ ២០១៥ ដល់ ១,៨% ក្នុងឆ្នាំ ២០១៦ ដោយសារភាពល្អប្រសើរនៃកត្តាអាកាសធាតុ ដោយទឹកភ្លៀងធ្លាក់រាយប៉ាយបានល្អគួបផ្សំនឹងការកើនឡើងកម្ពស់ទឹកទន្លេ។ វិស័យឧស្សាហកម្មនៅរក្សាបានកំណើនខ្ពស់ ២ ខ្ទង់ ទោះបីជាការកើននេះមានលក្ខណៈយឺតជាងមុនបន្តិចពី ១១,៧% មកត្រឹម ១០,៥% ដោយសារការថមថយកំណើនក្នុងវិស័យកាត់ដេរ ដែលបណ្តាលមកពីកំណើនសេដ្ឋកិច្ចយឺតនៃប្រទេសដៃគូពាណិជ្ជកម្មកម្ពុជា, ការបន្តកើនឡើងបៀវត្សអប្បបរមា និងការប្រកួតប្រជែងកាន់តែខ្លាំងពីបណ្តាប្រទេសនានា ខណៈដែលវិស័យសំណង់នៅបន្តកំណើនរឹងមាំ ទោះបីកំពុងស្ថិតក្នុងដំណាក់កាលកែសម្រួលទីផ្សារ ព្រមទាំងមានការប៉ះប៉ូវបន្ថែមដោយ

កំណើនល្អប្រសើរនៃឧស្សាហកម្មមិនមែនកាត់ដេរ សម្រាប់បម្រើការនាំចេញ និងប្រើប្រាស់ក្នុងស្រុក។ ទន្ទឹមនេះ វិស័យសេវាកម្មនៅតែបន្តកំណើនរឹងមាំ ទោះបីជាមានការថមថយបន្តិចបន្តួច ពី ៧,១% មកត្រឹម ៦,៧% នៅឆ្នាំ ២០១៦ ហើយដែលកំណើននេះត្រូវបានទ្រទ្រង់ដោយកំណើនល្អប្រសើរនៃវិស័យលក់ដុំ និងលក់រាយ, វិស័យដឹកជញ្ជូននិងទូរគមនាគមន៍ និងសេវាសាធារណៈផ្សេងៗ រួមមាន សេវារដ្ឋបាលសាធារណៈ និងសេវាអប់រំជាដើមក្នុងខណៈដែលវិស័យសណ្ឋាគារនិងភោជនីយដ្ឋាន និងវិស័យអចលនទ្រព្យ ត្រូវបានមើលឃើញថាមានកំណើនយឺតជាងមុនបន្តិច។ ក្នុងឆ្នាំ ២០១៦ អតិផរណាជាមធ្យមស្ថិតក្នុងអត្រា ៣,០% និងអត្រាប្តូរប្រាក់ជាមធ្យមគឺ ៤ ០៥៦ រៀល ក្នុងមួយដុល្លារសហរដ្ឋអាមេរិក។

| កំណើនពិត | ២០១៥ | ២០១៦ ប៉ាន់. | ២០១៧ ប៉ាន់. |
|---|---|---|---|
| **វិស័យកសិកម្ម** | **០,២%** | **១,៨%** | **២,០%** |
| ដំណាំ | ០,៣% | ២,៣% | ២,១% |
| ការចិញ្ចឹមសត្វ | ០,០% | ០,៥% | ១,៤% |
| ជលផល | ០,៣% | ១,៨% | ២,៦% |
| ព្រៃឈើ | -០,៨% | -១,៦% | -១,៧% |
| **វិស័យឧស្សាហកម្ម** | **១១,៧%** | **១០,៥%** | **៩,២%** |
| កាត់ដេរ | ៩,៨% | ៨,០% | ៥,៨% |
| សំណង់ | ១៩,២% | ១៥,៩% | ១៤,៤% |
| អនុវិស័យឧស្សាហកម្មផ្សេងទៀត | ៩,៣% | ១១,៦% | ១២,៥% |
| **វិស័យសេវាកម្ម** | **៧,១%** | **៦,៧%** | **៧,២%** |
| សណ្ឋាគារ និងភោជនីយដ្ឋាន | ២,៤% | ២,២% | ៥,២% |
| លក់ដុំ និងលក់រាយ | ៧,៧% | ៧,៤% | ៧,៨% |
| ដឹកជញ្ជូន និងទូរគមនាគមន៍ | ៨,០% | ៧,៦% | ៧,៣% |
| អចលនទ្រព្យ | ១១,៩% | ៩,៥% | ៨,៧% |
| អនុវិស័យសេវាកម្មផ្សេងទៀត | ៥,៦% | ៥,៩% | ៦,៨% |
| **កំណើន ផសស ពិត** | **៧,០%** | **៧,០%** | **៦,៩%** |

*ប្រភព៖ លេខជាក់ស្តែងវិទ្យាស្ថានជាតិស្ថិតិ (២០១៥) និងការប៉ាន់ស្មានរបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ (២០១៦ និង ២០១៧)*

យោងតាមការប៉ាន់ស្មាន ដោយផ្អែកតាមទិន្នន័យស្ថិតិជាក់ស្តែងរបស់ស្ថាប័នពាក់ព័ន្ធក្នុងរយៈពេលប៉ុន្មានខែដើមឆ្នាំ ២០១៧ នេះ សេដ្ឋកិច្ចកម្ពុជាអាចនឹងនៅតែបន្តកំណើនរឹងមាំក្នុងរង្វង់ ៦,៩% ក្នុងឆ្នាំ ២០១៧ ទោះបីទាបជាងការប៉ាន់ស្មានកាលពីដើមឆ្នាំបន្តិច ដែលកំណើននេះត្រូវបានគាំទ្រដោយកំណើនរឹងមាំនៃវិស័យសំណង់ និងវិស័យកសិកម្ម និងកំណើនខ្ពស់លើសការរំពឹងទុកនៃវិស័យទេសចរណ៍។

វិស័យកសិកម្ម ត្រូវបានព្យាករណ៍ថានឹងបន្តកំណើនរឹងមាំ ដូចដែលបានព្យាករណ៍កាលពីដើមឆ្នាំ ក្នុងរង្វង់ ២,០% នៅឆ្នាំ ២០១៧ ដោយសារភាពអំណោយផលនៃកត្តាអាកាសធាតុដែលនៅតែបន្ត ផ្អែកតាមការព្យាករណ៍របស់ក្រសួងធនធានទឹក និងឧតុនិយម, លទ្ធភាពស្រោចស្រពប្រសើរជាងមុន និងកំណើនល្អប្រសើរនៃវិស័យវារីវប្បកម្ម ការចិញ្ចឹមសត្វ និងដំណាំផ្សេងៗ ដោយសារការកើនឡើងនៃការវិនិយោគរបស់រដ្ឋលើវិស័យដំណាំ និងវិនិយោគឯកជនតាមបែបកិច្ចសន្យាលើការចិញ្ចឹមសត្វនិងត្រី គួបផ្សំនឹងការបន្តកើនឡើងថ្លៃកៅស៊ូ និងការងើបឡើងវិញនៃថ្លៃកសិផលទូទៅលើទីផ្សារអន្តរជាតិ។ ទន្ទឹមនេះ

វិស័យកសិកម្មក៏ត្រូវបានរំពឹងថានឹងមានភាពប្រសើរជាងមុន តាមរយៈកិច្ចប្រឹងប្រែងរបស់រាជរដ្ឋាភិបាលក្នុងការដាក់ចេញ និងអនុវត្តនូវវិធានការគោលនយោបាយអាទិភាពមួយចំនួន ដើម្បីដោះស្រាយបញ្ហាប្រឈមដែលវិស័យនេះកំពុងជួបប្រទះ រួមមាន បញ្ហាពូជសុទ្ធ, ផលិតភាពកសិកម្ម, ការផ្សព្វផ្សាយកសិកម្ម, ថ្លៃដើមផលិតខ្ពស់, ការកែច្នៃ, ការធ្វើពិពិធកម្ម, ពាណិជ្ជូបនីយកម្ម និងការស្វែងរកទីផ្សារថ្មីៗសម្រាប់កសិផលកម្ពុជា។

វិស័យឧស្សាហកម្ម ត្រូវបានព្យាករណ៍ថានឹងមានកំណើនថមថយបន្តិចក្នុងអត្រាប្រមាណ ៩,២% នៅឆ្នាំ ២០១៧ ដោយសារការថយចុះនៃកំណើនក្នុងវិស័យកាត់ដេរ ទោះបីត្រូវបានប៉ះប៉ូវមកវិញដោយកំណើនរឹងមាំនៃវិស័យឧស្សាហកម្មមិនមែនកាត់ដេរ និងការរក្សាបានកំណើនខ្ពស់ក្នុងវិស័យសំណង់។ វិស័យកាត់ដេររំពឹងថានឹងមានកំណើនថមថយមកត្រឹម ៥,៨% ដែលស្តែងចេញតាមរយៈការថមថយនៃការនាំចេញផលិតផលកាត់ដេរ និងការនាំចូលវត្ថុធាតុដើម ដែលទទួលរងនូវសម្ពាធមួយចំនួន ដូចជាការបន្តកើនឡើងនៃប្រាក់ឈ្នួលអប្បបរមា ការប្រកួតប្រជែងខ្លាំងជាងមុនពីប្រទេសមីយ៉ាន់ម៉ា, បង់ក្លាដែស និងវៀតណាម និងភាពស្ទាក់ស្ទើរនៃការបញ្ជាទិញផលិតផលកាត់ដេរមួយចំនួនដែលត្រូវប្រើរយៈពេលផលិតខ្លី, ដោយសារការបារម្ភនឹងភាពមិនប្រាកដប្រជានៃការបញ្ជូនទំនិញបានទាន់ពេលវេលា។ វិស័យសំណង់ត្រូវបានព្យាករណ៍ថានឹងនៅបន្តកំណើនរឹងមាំ និងស្ថិតក្នុងគន្លងមួយដែលមាននិរន្តរភាពជាងមុន ទោះបីមានការថមថយបន្តិចមកត្រឹម ១៤,៤% ដោយសារឥរិយាបថរង់ចាំមើលរបស់វិនិយោគិនចំពោះព្រឹត្តិការណ៍បោះឆ្នោត ដែលខិតជិតមកដល់ និងវិធានការរឹតត្បិតរបស់ធនាគារជាតិនៃកម្ពុជាក្នុងការផ្តល់ឥណទានទៅវិស័យនេះ។ សកម្មភាពសាងសង់នៅតែបន្តកំណើនខ្ពស់ ទោះបីមានការថមថយនៃគម្រោងសំណង់លំនៅដ្ឋានដែលមានតម្លៃខ្ពស់ ប៉ុន្តែត្រូវបានជំនួសវិញដោយសំណង់លំនៅដ្ឋានដែលមានតម្លៃសមរម្យ និងសំណង់ផ្សារទំនើប ព្រមជាមួយនឹងកំណើនវិនិយោគសាធារណៈលើហេដ្ឋារចនាសម្ព័ន្ធរូបវន្ត។ ជាមួយគ្នានេះ ការថមថយនៃវិស័យឧស្សាហកម្ម ជារួមក៏បានបំពេញវិញខ្លះដោយកំណើនខ្ពស់នៃវិស័យឧស្សាហកម្មមិនមែនកាត់ដេរ, គ្រឿងបង្គុំអេឡិចត្រូនិច, គ្រឿងបន្លាស់, ម្ហូបអាហារ និងភេសជ្ជៈ, កង់, និងគ្រឿងសង្ហារឹមជាដើម ក្នុងអត្រាប្រមាណ ១២,៥% ដែលត្រូវបានឆ្លុះបញ្ចាំងតាមរយៈកំណើនតម្លៃផលិតកម្ម និងការនាំចេញ។

ចំណែកវិស័យសេវាកម្ម ត្រូវបានព្យាករណ៍ថានឹងមានកំណើនល្អប្រសើរជាងឆ្នាំ ២០១៦ ដោយអាចសម្រេចបានក្នុងរង្វង់ ៧,២៣% ក្នុងឆ្នាំ ២០១៧ ដោយសារកំណើនរឹងមាំលើសពីការរំពឹងទុកនៃវិស័យទេសចរណ៍ និង វិស័យលក់ដុំនិងលក់រាយ ទោះបីជាវិស័យដឹកជញ្ជូននិងគមនាគមន៍ និង វិស័យអចលនទ្រព្យអាចនឹងមានកំណើនថមថយបន្តិច។ វិស័យទេសចរណ៍ ត្រូវបានព្យាករណ៍ថាមានកំណើនខ្ពស់រហូតដល់ ៥,២% ដោយសារតែការកើនឡើងនៃភ្ញៀវទេសចរបរទេស ជាពិសេសភ្ញៀវដែលធ្វើដំណើរតាមជើងអាកាស។ ជាការគួរឱ្យកត់សម្គាល់ ភ្ញៀវដែលចំណាយខ្ពស់ដូចជា រុស្ស៊ី និងជប៉ុន បានបន្តកើនឡើងខ្ពស់ធៀបនឹងឆ្នាំ ២០១៦ ខណៈដែលភ្ញៀវទេសចរចិនបានឡើងឈរក្នុងលំដាប់ថ្នាក់លេខ១។ ភាពល្អប្រសើរនៃវិស័យនេះត្រូវបានឆ្លុះបញ្ចាំងដោយភាពអំណោយផលជាងមុននៃស្ថានភាពសេដ្ឋកិច្ចខាងក្រៅ, ការបង្កើនជើងហោះហើរត្រង់ទៅកាន់ប្រទេសជប៉ុន, ខេត្តមួយចំនួននៃប្រទេសចិន, តៃវ៉ាន់ និងប្រទេសអារ៉ាប់រួមជាដើម, ការអនុវត្តគោលនយោបាយផ្តល់ជូនជាពិសេសសម្រាប់ភ្ញៀវទេសចរចិន (China Ready) និងការទទួលស្គាល់ជាអន្តរជាតិជាប់ៗគ្នាថាកម្ពុជាជាតំបន់រមណីយដ្ឋានទេសចរណ៍វប្បធម៌ និងប្រវត្តិសាស្ត្រល្បីល្បាញមួយប្រចាំទ្វីបអាស៊ី។

ដោយឡែកវិស័យអចលនទ្រព្យ ត្រូវបានព្យាករណ៍ថានឹងមានកំណើនក្នុងអត្រាយឺតជាងមុនត្រឹម ៨,៧% ដោយសារភាពស្ទាក់ស្ទើរនៃការវិនិយោគនៅក្នុងដំណាក់កាលនៃការខិតចូលមកដល់នៃការបោះឆ្នោតសកលនាពេលខាងមុខ និងការថមថយនៃឥណទានដែលផ្ដល់ឱ្យវិស័យនេះ ប៉ុន្តែតម្រូវការនៃសំណង់លំនៅដ្ឋានថ្លៃសមរម្យ និងផ្សារទំនើប ត្រូវបានមើលឃើញថានៅបន្តកំណើនខ្ពស់។ កំណើននៃវិស័យដឹកជញ្ជូន និងគមនាគមន៍ ត្រូវបានប៉ាន់ស្មានថានឹងបន្តថមថយមកត្រឹម ៧,៣% ដោយសារកំណើនយឺតនៃវិស័យផ្សេងៗទៀត ដូចជាកាត់ដេរ និងសំណង់ ដែលឆ្លុះបញ្ចាំងតាមរយៈការថយចុះនៃការនាំចូលរថយន្តដឹកជញ្ជូនក៏ដូចជាការនាំចូលប្រេងសាំង។ ដោយឡែក ការថមថយកំណើននៃវិស័យខាងលើ ត្រូវបានបំពេញបន្ថែមខ្លះដោយកំណើនខ្ពស់នៃវិស័យលក់ដុំ និងលក់រាយក្នុងអត្រា ៧,៨% ដូចដែលបានព្យាករណ៍កាលពីដើមឆ្នាំ ដែលកំណើននេះ ត្រូវបានគាំទ្រដោយកំណើននៃលទ្ធភាពចំណាយរបស់ប្រជាពលរដ្ឋ ដោយសារគោល-នយោបាយវិត្តារកម្មរបស់រាជរដ្ឋាភិបាលក្នុងការបង្កើនប្រាក់ខែដល់មន្ត្រីរាជការនិងកំណើនប្រាក់ឈ្នួលអប្បបរមា រួមទាំងការផ្លាស់ប្តូររបៀបរបបរស់នៅរបស់យុវវ័យដែលចូលចិត្តចំណាយខាងក្រៅ។

គិតត្រឹមខែឧសភា ឆ្នាំ ២០១៧ នេះ អត្រាអតិផរណាមធ្យមប្រចាំឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានថានឹងរក្សាបាននូវអត្រា ៣,៨% ដូចគ្នានឹងការព្យាករណ៍កាលពីដើមឆ្នាំដោយសារតែការងើបឡើងវិញជាបណ្តើរៗនៃថ្លៃប្រេងលើទីផ្សារអន្តរជាតិ និងតម្លៃកសិផលមួយចំនួន។ រីឯអត្រាប្តូរប្រាក់វិញ គិតត្រឹមខែ ឧសភា ឆ្នាំ ២០១៧ មានតម្លៃ ៤ ០៤៩ រៀល ក្នុងមួយដុល្លារអាមេរិក។ ទុនបម្រុងអន្តរជាតិរបស់កម្ពុជារំពឹងថានឹងកើនដល់ ៧ ៥០០ លានដុល្លារអាមេរិក ដែលអាចទ្រទ្រង់ការនាំចូលបានប្រមាណជា ៥,៧ ខែ នៅក្នុងឆ្នាំ២០១៧។

ផ្អែកតាមការព្យាករណ៍ចុងក្រោយរបស់មូលនិធិរូបិយវត្ថុអន្តរជាតិនាខែ មេសា ឆ្នាំ ២០១៧ នេះ សេដ្ឋកិច្ចពិភពលោកត្រូវបានព្យាករណ៍ថានឹងមានភាពល្អប្រសើរជាងមុនបន្តិចពី ៣,៥% ឆ្នាំ២០១៧ ទៅ ៣,៦%ឆ្នាំ២០១៨ ដោយសារការងើបឡើងវិញបន្តិចនៃពាណិជ្ជកម្មសកល និងវិស័យកម្មន្តសាល និងទីផ្សារហិរញ្ញវត្ថុ ជាពិសេសមានការរំពឹងទុកថាកំណើនសេដ្ឋកិច្ចល្អប្រសើរនៃបណ្តាប្រទេសដៃគូនាំចេញសំខាន់ៗរបស់កម្ពុជា រួមមានអាមេរិក, អឺរ៉ុប និងជប៉ុន ខណៈដែលអាស៊ីនៅតែបន្តជាមជ្ឈមណ្ឌលកំណើនសេដ្ឋកិច្ចពិភពលោកក្នុងឆ្នាំ ២០១៧ និង២០១៨ ទោះបីកំណើនសេដ្ឋកិច្ចចិនមាននិន្នាការថមថយបន្តិចក៏ដោយ។

ទន្ទឹមនឹងទស្សនវិស័យនេះ សេដ្ឋកិច្ចកម្ពុជាក៏អាចនឹងជួបប្រទះនូវហានិភ័យមួយចំនួន ដូចជា៖ (១)-ហានិភ័យខាងក្រៅ៖ ភាពមិនប្រាកដប្រជានៃកំណើនសេដ្ឋកិច្ចក្នុងតំបន់ និងពិភពលោក ជាពិសេសប្រទេសដៃគូពាណិជ្ជកម្មសំខាន់ៗរបស់កម្ពុជា, ការរឹតត្បិតគោលនយោបាយពាណិជ្ជកម្ម និងរូបិយវត្ថុរបស់សហរដ្ឋអាមេរិក, ការបន្តថមថយនៃកំណើនសេដ្ឋកិច្ចចិន (ជាពិសេសការដាក់កំហិតលើលំហូរមូលធនទៅក្រៅប្រទេស), ភាពមិនប្រាកដប្រជាលើសការរំពឹងទុកនៃស្ថានភាពហិរញ្ញវត្ថុពិភពលោក, ឥទ្ធិពលអវិជ្ជមាននៃ Brexit លើការនាំចេញផលិតផលកាត់ដេរកម្ពុជា, ការបន្តកើនថ្លៃប្រេងសាំង, បញ្ហាអាកាសធាតុ, ភាពតានតឹងនៃភូមិសាស្ត្រនយោបាយ និងបញ្ហាអសន្តិសុខជាសកល (២)-បញ្ហាប្រឈម និងហានិភ័យក្នុងស្រុក៖ និន្នាការបន្តការកើនឡើងនូវថ្លៃម្ហូបអាហារ, ការថមថយនៃភាពប្រកួតប្រជែងរបស់កម្ពុជាដោយសារតែការកើនឡើងនៃប្រាក់ឈ្នួលពលកម្មលើសពីកំណើនផលិតភាព, ថ្លៃអគ្គិសនីនៅខ្ពស់នៅឡើយ, ប្រព័ន្ធដឹកជញ្ជូន និងឡជីស្ទិកនៅមានភាពទន់ខ្សោយ, សម្ពាធផ្នែកសារពើពន្ធស្របពេលដែលចំណាយថវិកាជាតិបន្តកើនឡើង

ជាពិសេស ចំណាយបន្ទុកបុគ្គលិក និងលទ្ធភាពនៃការកើតឡើងវិញនូវអស្ថិរភាពផ្នែកទំនាក់ទំនងវិជ្ជាជីវៈ មុនពេលបោះឆ្នោតសកលឆ្នាំ ២០១៨។

ជារួម ទោះបីស្ថានភាពសេដ្ឋកិច្ចកម្ពុជាបច្ចុប្បន្ននៅតែបន្តរីកចម្រើនក្នុងកម្រិតល្អយ៉ាងណាក្តី កម្ពុជាត្រូវបន្តការប្រុងប្រយ័ត្នខ្ពស់, ត្រួតពិនិត្យនិងតាមដានជាប្រចាំ ព្រមទាំងត្រៀមលក្ខណៈដាក់ចេញនូវគោល-នយោបាយ និងវិធានការចាំបាច់ឱ្យទាន់ពេលវេលាប្រកបដោយប្រសិទ្ធភាព និងភាពស័ក្តិសិទ្ធិ ដើម្បីបង្ការហានិភ័យ និងឆ្លើយតបទៅនឹងការប្រែប្រួលជាយថាហេតុណាមួយ ដើម្បីធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច និងកំណើនខ្ពស់ប្រកបដោយចីរភាព។

## ខ- លទ្ធផលនៃការអនុវត្តថវិកាឆមាសទី១ ឆ្នាំ ២០១៧

### ខ.១ ការអនុវត្តចំណូល

#### ខ.១.១ ចំណូលថ្នាក់ជាតិ

ខ.១.១.១ ចំណូលសរុបដែលកត់ត្រាដោយអគ្គនាយកដ្ឋានរតនាគារជាតិប្រចាំឆមាសទី ១ អនុវត្តបានចំនួន ៨ ៩៩៤ ៥៩២ លានរៀល ស្មើនឹង ៥៦,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៥៣,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់គឺកើនឡើង ២១,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលក្នុងនោះ៖

**ចំណូលចរន្ត** អនុវត្តបានចំនួន ៨ ៦០២ ៦៥៧ លានរៀល ស្មើនឹង ៥៥,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៥៤,៨% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់គឺកើនឡើង ១៧,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលក្នុងនោះ ចំណូលសារពើពន្ធ អនុវត្តបានចំនួន ៧ ៦៨០ ០៤៤ លានរៀល ស្មើនឹង ៥៨,១% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៥៧,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់ គឺកើនឡើង ១៥,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ និង ចំណូលមិនមែនសារពើពន្ធ អនុវត្តបានចំនួន ៩២២ ៦១៣ លានរៀល ស្មើនឹង ៤០,២% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាងរយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបានតែ ៣៩,៣% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណូលជាសាច់ប្រាក់គឺកើនឡើង ២៦,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ជារួម ទាំងចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធអនុវត្តបានល្អតាមផែនការនៃច្បាប់ហិរញ្ញវត្ថុ និងអនុវត្តបានខ្ពស់ជាងឆ្នាំ ២០១៦ ធៀបរយៈពេល ៦ ខែដើមឆ្នាំ ដូចគ្នា។

**ចំណូលមូលធន** អនុវត្តបានចំនួន ៣៧០ ៧៧៨ លានរៀល គឺស្មើនឹង ៩៣,១% នៃច្បាប់ហិរញ្ញវត្ថុ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ គឺមានកំណើនខ្ពស់ខ្លាំងដោយសារ (១)-ការរំកិលនូវការដកសាច់ប្រាក់ពីផែនការឆ្នាំ ២០១៦ មកក្នុងឆ្នាំ ២០១៧ នេះ ព្រោះរាជរដ្ឋាភិបាលកម្ពុជាទើបបានបំពេញលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសម្រាប់ការដកសាច់ប្រាក់ និង (២)-ការបំពេញលក្ខខណ្ឌនៃកិច្ចព្រមព្រៀងសម្រាប់ការដកសាច់ប្រាក់បានទាន់ពេលវេលាសម្រាប់ផែនការឆ្នាំ ២០១៧។ ក្នុងនោះ ចំណូលមូលធនក្នុងប្រទេសអនុវត្តបានចំនួន ៥៤ ៩៥៧ លានរៀល ស្មើនឹង ៣៧,០% នៃច្បាប់ហិរញ្ញវត្ថុ គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២៤,២% នៃច្បាប់ហិរញ្ញវត្ថុ និង**ចំណូលមូលនិធិទ្រទ្រង់ថវិកា** ដែលហិរញ្ញប្បទានពីបរទេសអនុវត្តបានចំនួន ៣១៥ ៨២១ លានរៀល ស្មើនឹង ១២៦,៣% នៃ

ច្បាប់ហិរញ្ញវត្ថុ។ ជារួម ចំណូលមូលធនសម្រេចបានលទ្ធផលល្អប្រសើរជាងឆ្នាំ ២០១៦ ធៀបនឹងរយៈពេល ៦ ខែដើមឆ្នាំដូចគ្នា។ ដូច្នេះ, តាមការប៉ាន់ស្មាន, ចំណូលពីប្រភពនេះក្នុងឆ្នាំ ២០១៧ អាចសម្រេចបានលើសច្បាប់ហិរញ្ញវត្ថុប្រមាណ ២៣,៥%។

**ខ.១.១.២ ចំណូលសារពើពន្ធ** សរុបសម្រាប់ឆមាសទី ១ ឆ្នាំ ២០១៧ អនុវត្តបាន ៥៨,១% នៃច្បាប់ហិរញ្ញវត្ថុដែលក្នុងនោះ៖

• **ចំណូលគយនិងរដ្ឋាករ** អនុវត្តបានចំនួន ៣ ៦៩១ ៤៨៤ លានរៀល ស្មើនឹង ៥០,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺទាបជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៥៣,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ចំណូលគយនិងរដ្ឋាករកើនឡើង ៤,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដោយសារកាលពីឆ្នាំ ២០១៦ ចំណូលមានកំណើនខ្ពស់យ៉ាងខ្លាំងដល់ចំណុចកំពូលតាមរយៈវិធានការគោលនយោបាយពន្ធ គឺការដាក់ឱ្យអនុវត្តនូវអនុក្រឹត្យស្តីពីអាករពិសេសចាប់ពីថ្ងៃទី ០១ ខែមេសា ឆ្នាំ ២០១៦ បានធ្វើឱ្យមានការសម្រុកនាំចូលរថយន្តយ៉ាងខ្លាំងនៅត្រីមាសទី ១ គួបផ្សំនឹងការអនុវត្តនូវយុទ្ធនាការប្រមូលពន្ធអាករលើយានយន្តនិងរថយន្តចង្កូតស្តាំមិនទាន់បង់ពន្ធ ដែលកំពុងប្រើប្រាស់នៅក្នុងប្រទេស។ ចំណូលនេះអាចរក្សាស្ថិរភាពបានក្នុងឆ្នាំ ២០១៧ ដោយសារការពង្រឹងការអនុវត្តវិធានការកាន់តែមុតស្រួច និងប្រកបដោយបុរេសកម្ម ទាំងវិធានការរដ្ឋបាល និងវិធានការគោលនយោបាយពន្ធ ព្រមជាមួយនឹងការបន្តអនុវត្តនូវយុទ្ធនាការប្រមូលពន្ធអាករលើយានយន្តដែលកំពុងប្រើប្រាស់នៅក្នុងប្រទេស ស្របតាម **យុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨** ដែលអគ្គនាយកដ្ឋានគយនិងរដ្ឋាករបាន និងកំពុងអនុវត្តប្រកប-ដោយប្រសិទ្ធភាព និងយ៉ាងសកម្ម។ ទន្ទឹមនេះ គួរកត់សម្គាល់ថា ចំណូលបាត់បង់ដោយសារការអនុវត្តកិច្ចព្រមព្រៀងពាណិជ្ជកម្មសេរី ក្នុងក្របខណ្ឌអាស៊ាន និងរវាងអាស៊ាន ជាមួយដៃគូអាស៊ានផ្សេងទៀតសរុបក្នុងឆមាសទី ១ ឆ្នាំ ២០១៧ ក៏មានរហូតដល់ ៣៩៣ ១៤០ លានរៀល ផងដែរ។

បើពិនិត្យលើរចនាសម្ព័ន្ធពន្ធគយនិងរដ្ឋាករឃើញថា (១)-ពន្ធលើការនាំចូលអនុវត្តបាន ៤៣,៩% នៃច្បាប់ហិរញ្ញវត្ថុ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ គឺមានការធ្លាក់ចុះ ៩,៦%, (២)-ពន្ធលើការនាំចេញអនុវត្តបាន ៣៦,៥% នៃច្បាប់ហិរញ្ញវត្ថុ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ គឺមានកំណើន ៣១,៨% (៣)-អាករពិសេសលើការនាំចូលអនុវត្តបាន ៦០,៩% នៃច្បាប់ហិរញ្ញវត្ថុ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ គឺមានកំណើន ១៦,៣% និង(៤)-អាករតម្លៃបន្ថែមលើការនាំចូលអនុវត្តបាន ៤៧,៧% នៃច្បាប់ហិរញ្ញវត្ថុ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ គឺមានការកើនឡើង ៣,៧%។

ទន្ទឹមនេះ បើពិនិត្យលើប្រភពចំណូលសំខាន់ៗឃើញថា៖

- ចំណូលពីការនាំចូលប្រេងឥន្ធនៈដែលគ្របដណ្តប់ ២៣,៨៨% នៃចំណូលសរុប បានកើនឡើង ៩,១%។ បរិមាណនៃការនាំចូលប្រេងសាំងកើនឡើង ៨,៣៨%, ប្រេងម៉ាស៊ូតកើនឡើង ០,៣១%, ប្រេងយន្តហោះកើនឡើង ៤៩,១២%, ប្រេងខ្មៅមានការធ្លាក់ចុះ ៤៨,១៦%, ហ្គាសកើនឡើង ១៥,២១%, ថាមពលអគ្គិសនីថយចុះ -៦,០%។ ប្រការនេះបានបង្ហាញពីកំណើនសេដ្ឋកិច្ច ហើយតម្រូវការទីផ្សារកើនឡើង គួបផ្សំនឹងថ្លៃប្រេងនៅទីផ្សារអន្តរជាតិមានការកើនឡើង និងជាពិសេសលទ្ធផលល្អប្រសើរនៃការដាក់ចេញ

នូវវិធានការតឹងរ៉ឹងក្នុងការគ្រប់គ្រងផលិតផលតេលសិលា ដែលមុខទំនិញនេះអាចជួយរក្សាស្ថេរភាពចំណូលបានមួយផ្នែក,

- ចំណូលពីការនាំចូលយានយន្តដែលគ្របដណ្តប់ ៣៩,៥៩%នៃចំណូលសរុប មានការធ្លាក់ចុះ ៧,៨៤%។ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ បរិមាណនៃការនាំចូលរថយន្តធ្លាក់ចុះ ១៤,៨២% (ពី ៣៥ ៧៩៨ គ្រឿង នៅឆ្នាំ ២០១៦ មក ៣០ ៤៩៣ គ្រឿង នៅឆ្នាំ ២០១៧) ការធ្លាក់ចុះនេះ គឺដោយសារគោលនយោបាយកែសម្រួលអាករពិសេសដែលត្រូវបានដាក់ឱ្យអនុវត្តនៅថ្ងៃទី ០១ ខែ មេសា ឆ្នាំ ២០១៦ បានធ្វើឱ្យធុរជនសម្រុកនាំចូលរថយន្តនៅត្រីមាសទី១ ឆ្នាំ២០១៦។

- ចំណូលពីការនាំចូលទំនិញផ្សេងៗ ដែលគ្របដណ្តប់ ៣៦,៩០% នៃចំណូលសរុប មានកំណើន ១៦,៦៥% ដែលបានជួយរក្សាស្ថេរភាពចំណូលបានមួយផ្នែកធំ។ ការរីកចម្រើននៃសហគ្រាសធុនតូចនិងមធ្យម ដែលមានសមត្ថភាពផលិតជំនួសការនាំចូល ដូចជា គេសជ្ជៈ, គ្រឿងឧបភោគ-បរិភោគ និង គ្រឿងសំណង់ ជាដើម អាចធ្វើឱ្យចំណូលពីប្រភពនេះនឹងមានការធ្លាក់ចុះ។

• **ចំណូលពន្ធដារ** (ថ្នាក់ជាតិ) អនុវត្តបានចំនួន ៣ ៩៨៨ ៥៥៩ លានរៀល ស្មើនឹង ៦៧,៦% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាងរយៈពេល ដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៦២,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់ចំណូលពន្ធដារ មានកំណើន ២៩,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ គឺដោយសារៈ

- ពន្ធលើប្រាក់ចំណូលអនុវត្ត ៨២,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់ មានកំណើនរហូតដល់ ៣២,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដោយសារសហគ្រាសបង់ពន្ធលើប្រាក់ចំណូលបានបង់ថែម ហើយចំនួនសហគ្រាសមានការកើនឡើងចំនួន ១ ០៨៣ សហគ្រាស,

- ពន្ធលើប្រាក់បៀវត្សអនុវត្តបាន ៤៩,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាចំណូលសាច់ប្រាក់ មានកំណើន ៧,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦,

- អាករលើតម្លៃបន្ថែម (របបផ្ទៃក្នុង) អនុវត្តបាន ៦៣,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានកំណើន ៤១,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដោយសារការអនុវត្តប្រកបដោយប្រសិទ្ធភាពនូវវិធានការផ្ទៀងផ្ទាត់វិក្កយប័ត្រអាករ និងការធ្វើសវនកម្មលើលិខិតស្នាមភ្លាមៗក្នុងការប្រមូលពន្ធនេះ, ការបញ្ឈប់ប្រតិបត្តិការនាំចេញ-នាំចូល, ការបញ្ឈប់ការពិនិត្យគម្រោងវិនិយោគនាំចូលវត្ថុធាតុដើមនៅក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា,

- អាករពិសេសលើទំនិញ និងសេវាក្នុងស្រុក អនុវត្តបាន ៥៤,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់ មានកំណើន ១១,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦,

- ទន្ទឹមនេះ ពន្ធលើផលទុននៃដីធ្លីនិងផ្ទះសម្បែងអនុវត្តបាន ៥៣,៥% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណូលជាសាច់ប្រាក់ មានកំណើន ៣០,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ និង ប្រភេទនៃពន្ធផ្សេងៗទៀតអនុវត្តបាន ៤៧,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានកំណើន ៣៩,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ដោយឡែក អាករលើផលរបរ មិនត្រូវបានគ្រោងសម្រាប់ការអនុវត្តចំណូលទៀតនោះទេនៅក្នុងឆ្នាំ២០១៧ នេះ ដោយសាររាជរដ្ឋាភិបាល បានលុបចោលនូវប្រភេទពន្ធនេះ ទន្ទឹមគ្នានឹងការលុបចោលរបបម៉ៅការចាប់តាំងពីឆ្នាំ ២០១៦។

ខ.១.១.៣ **ចំណូលមិនមែនសារពើពន្ធ** អនុវត្តបានចំនួន ៩២២ ៦១៣ លានរៀល ស្មើនឹង ៤០,២% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបានត្រឹមតែ ៣៩,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានកំណើន ២៦,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដោយសារៈ

- **ចំណូលពីទ្រព្យសម្បត្តិរដ្ឋ** អនុវត្តបានចំនួន ៧៧ ៩០៣ លានរៀល ស្មើនឹង ៤៥,៩% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបានត្រឹមតែ ៤១,០% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានកំណើន ២០,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដោយសារចំណូលពីផលនេសាទ, ផលព្រៃឈើ, សម្បទានប្រេងកាតនិងរ៉ែ, ការជួលអចលនវត្ថុ និងចំណូលពីទ្រព្យ-សម្បត្តិរដ្ឋផ្សេងៗទៀតកើនឡើងខ្ពស់ ដោយសារមានការពង្រឹងយន្តការនៃការប្រមូលចំណូលលើមុខចំណូលទាំងនេះ។ លើកលែងតែចំណូលពីការជួលសហគ្រាស និងប្រាក់ចំណេញរបស់សហគ្រាសសាធារណៈ, បើគិតចំណូលជាសាច់ប្រាក់, មានការធ្លាក់ចុះ ៦,៨% និង ១៦,៨% រៀងៗគ្នា ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។

- **ចំណូលមិនមែនសារពើពន្ធផ្សេងទៀត ក្រៅពីទ្រព្យសម្បត្តិរដ្ឋ** អនុវត្តបាន ៣៩,៤% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣៨,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានកំណើន ២៨,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ហើយកំណើននេះបានមកពីលទ្ធផលល្អប្រសើរនៃការអនុវត្តចំណូលពីផលទុនរបស់អាកាសចរណ៍ស៊ីវិល, ផលទុននៃសកម្មភាពទេសចរណ៍, អាករនៃស្ថានទូត, ចំណូលពីអាជ្ញាបណ្ណក្នុងស្រុក, កម្រៃគ្រប់គ្រងនិងទិដ្ឋាការនាំចេញ។ ប៉ុន្តែបើគិតចំណូលជាសាច់ប្រាក់, ចំណូលពីផលទុនរបស់ប្រៃសណីយ៍និងទូរគមនាគមន៍ មានការធ្លាក់ចុះ១៣,៥% ហើយចំណូលពីការត្រួតពិនិត្យគុណភាពផលិតផល ក៏មានការធ្លាក់ចុះ ៧៥% ផងដែរ ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។

ទន្ទឹមនេះ ចំណូលកាតព្វកិច្ចពីកាស៊ីណូ និង ចំណូលកាតព្វកិច្ចពីឆ្នោត ក៏អនុវត្តបាន ៤៤,៧% នៃច្បាប់ហិរញ្ញវត្ថុដែរ នៅក្នុងឆមាសទី១ នៃឆ្នាំ ២០១៧ នេះ ហើយបើគិតចំណូលជាសាច់ប្រាក់មានកំណើន ២១,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។

**ខ.១.២. ចំណូលថ្នាក់ក្រោមជាតិ**

ចំណូលរបស់រដ្ឋបាលថ្នាក់ក្រោមជាតិ ក្នុងឆមាសទី១ ឆ្នាំ ២០១៧ អនុវត្តបានចំនួន ៦៧១ ៤៦១ លានរៀល ស្មើនឹង ៤១,៨% នៃច្បាប់ហិរញ្ញវត្ថុ, គឺខ្ពស់ជាងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបានត្រឹមតែ ៣៧,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណូលជាសាច់ប្រាក់មានកំណើន ៣៤,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ក្នុងនោះ **ចំណូលសារពើពន្ធ**អនុវត្តបានចំនួន ៣៤៤ ៦៧១ លានរៀល ស្មើនឹង ៣៧,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតជាសាច់ប្រាក់មានកំណើន ៣៧,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដោយសារមានការកើនឡើងនូវចំណូលពន្ធប្រថាប់ត្រា។ **ចំណូលមិនមែនសារពើពន្ធ**អនុវត្តបានចំនួន ១២ ០២១ លានរៀល ស្មើនឹង ២៩,២% នៃច្បាប់ហិរញ្ញវត្ថុ និង **ចំណូលឧបត្ថម្ភធនពីថវិការដ្ឋ**ចំនួន ៣១៤ ៧៦៩ លានរៀល ស្មើនឹង ៤៩,៣% នៃច្បាប់ហិរញ្ញវត្ថុ។ ដូច្នេះ តាមការប៉ាន់ស្មានរហូតដល់ដំណាច់ឆ្នាំ ២០១៧ ចំណូលថ្នាក់ក្រោមជាតិ អាចនឹងសម្រេចបានលើសច្បាប់ហិរញ្ញវត្ថុប្រមាណ ២០,៣%។

## ខ-២ ការអនុវត្តចំណាយ

### ខ-២-១ ចំណាយថ្នាក់ជាតិ

**ខ.២.១.១ ចំណាយសរុបឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ** ប្រចាំឆមាសទី១ ឆ្នាំ ២០១៧ តាមអាណត្តិបើកប្រាក់ (**មិនទាន់គិតបុរេប្រទាន**) អនុវត្តបានចំនួន ៥ ៦៨៥ ៨៦៦លានរៀល ស្មើនឹង ៣៥,៨% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ០,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣៤,៩% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ១៩,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលក្នុងនោះ **ចំណាយចរន្ត** អនុវត្តបានចំនួន ៥ ០១៩ ០២៦ លានរៀល ស្មើនឹង ៣៨,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ២,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣៦,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២៣,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ **ចំណាយមូលធន** អនុវត្តបានចំនួន ៦៦៦ ៨៣៩ លានរៀល ស្មើនឹង ២៣,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាងចំនួន ៥,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២៨,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់ថយចុះ ៣,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ **បើគិតទាំងចំណាយតាមបុរេប្រទាន** ដែលមានចំនួនប្រមាណ ៥៩៨ ៧៩៨ លានរៀល (ចំណាយចរន្ត និងចំណាយមូលធន) ចំណាយសរុបឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិ ប្រចាំឆមាសទី ១ ឆ្នាំ ២០១៧ អនុវត្តបាន ៦ ២៨៤ ៦៦៤ លានរៀល ស្មើនឹង ៣៩,៥% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ ចំណាយចរន្តអនុវត្តបាន ៤១,១% នៃច្បាប់ហិរញ្ញវត្ថុ និងចំណាយមូលធនអនុវត្តបាន ៣២,៥% នៃច្បាប់ហិរញ្ញវត្ថុ។

**ខ.២.១.២ ចំណាយចរន្តសរុបសម្រាប់ឆមាសទី ១ ឆ្នាំ ២០១៧** អនុវត្តបាន ៣៨,៥% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាង ២,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣៦,៤% នៃច្បាប់ហិរញ្ញវត្ថុ ក្នុងនោះ៖

-**ចំណាយបន្ទុកបុគ្គលិក** ដែលមានសមាមាត្រ ៥២,១៤% នៃចំណាយចរន្តថ្នាក់ជាតិសរុប អនុវត្តបានរហូតដល់ចំនួន ៣ ០៨៧ ៨០៦ លានរៀល ស្មើនឹង ៤៥,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនប្រហាក់-ប្រហែលរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៤៥,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២១,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ចំណាយលើបៀវត្ស គឺអនុវត្តបានល្អប្រសើរដោយសារការអនុវត្តប្រកបដោយប្រសិទ្ធភាពនៃការបើកបៀវត្សប្រចាំខែបានប្រព្រឹត្តទៅរលូន និងទៀងទាត់នៅក្នុងសប្តាហ៍ទី ៤ នៃខែនីមួយៗ តាមប្រព័ន្ធធនាគារ។

-**ចំណាយមិនមែនបន្ទុកបុគ្គលិក** ដែលមានសមាមាត្រ ៤៧,៨៦% នៃចំណាយចរន្តថ្នាក់ជាតិសរុប អនុវត្តបានចំនួន ១ ៩៣១ ២២០ លានរៀល ស្មើនឹង ៣០,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ៣,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២៧,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២៨,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដោយសារក្រសួង-ស្ថាប័នអនុវត្តថវិកាកម្មវិធីពេញលេញបានយល់ដឹងកាន់តែច្បាស់អំពីនីតិវិធីនៃការអនុវត្តថវិកាកម្មវិធី ដែលនាំឱ្យអង្គភាពថវិកាក្រោមឱវាទអនុវត្តបានទាន់ពេលវេលាជាងមុននូវការស្នើសុំទូទាត់រជ្ជទេយ្យបុរេប្រទាន,

ការស្នើសុំធានាចំណាយ និងការអនុវត្តកិច្ចលទ្ធកម្មសាធារណៈ ព្រមទាំងការអនុវត្តថវិកាកាន់តែមានភាពប្រសើរឡើងតាមប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (FMIS)។

**ខ.២.១.៣ បើពិនិត្យមើលការអនុវត្តចំណាយចរន្តតាមវិស័យឃើញថា៖**

- **វិស័យរដ្ឋបាលទូទៅ** អនុវត្តបានចំនួន ៨១៩ ៩៧១ លានរៀល ស្មើនឹង ៤១,៣% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ១,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣៩,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២៩,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ២៥០ ៦៣០ លានរៀល ស្មើនឹង ៤៨,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាងចំនួន ២,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៥០,៩% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារក្រសួង-ស្ថាប័នមួយចំនួនស្ថិតក្នុងដំណាក់កាលនៃការជ្រើសរើសក្របខណ្ឌមន្ត្រីថ្មី និងមានការយឺតយ៉ាវក្នុងបោះផ្សាយអាណត្តិបើកប្រាក់ដើម្បីទូទាត់ប្រាក់រង្វាន់ពីសេវាសាធារណៈ, ប៉ុន្តែបើគិតចំណាយជាសាច់ប្រាក់កើនឡើង ១៥,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៥៦៩ ៣៤០ លានរៀល ស្មើនឹង ៣៨,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ៣,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣៥,៦% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៣៦,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។
- **វិស័យការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ** អនុវត្តបានចំនួន ១ ៤០៤ ៤៨១ លានរៀល ស្មើនឹង ៤២,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនប្រហាក់ប្រហែលនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៤២,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ១៨,៧% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានតែចំនួន ១ ២១១ ៤១៣ លានរៀល ស្មើនឹង ៤៦,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាងចំនួន ២,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៤៨,៨% នៃច្បាប់ហិរញ្ញវត្ថុ ដោយសារចំណាយសម្រាប់ឧបត្ថម្ភនិវត្តជន ក្នុងក្របខណ្ឌមន្ត្រីនគរបាលជាតិនៅក្នុងឆមាសទី១ កំពុងដំណើរការនីតិវិធីដើម្បីដកសាច់ប្រាក់នៅឡើយ, ប៉ុន្តែបើគិតចំណាយជាសាច់ប្រាក់កើនឡើង ២០,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ១៩៣ ០៦៩ លានរៀល ស្មើនឹង ២៦,១% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ០,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២៥,២% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៦,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។
- **វិស័យសង្គមកិច្ច** អនុវត្តបានចំនួន ១ ៩៥១ ៩៦៧ លានរៀល ស្មើនឹង ៤០,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ៣,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣៧,១% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២២,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ១ ៤៨៣ ២៣០ លានរៀល ស្មើនឹង ៤៥,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ២,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៤៣,៣% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២២,២% ធៀបនឹង

រយៈពេលដូចគ្នា ក្នុងឆ្នាំ ២០១៦។ ជារួម ការបើកផ្តល់ប្រាក់បៀវត្ស និងប្រាក់សោធននិវត្តន៍ ដំណើរការបានល្អនិងទាន់ពេលវេលា ប៉ុន្តែចំណាយបន្ទុកបុគ្គលិកនេះនៅទាបជាង ៥០% ដោយសារមុខចំណាយផ្សេងទៀត ដូចជា ការជ្រើសរើសក្របខណ្ឌថ្មី និងការទូទាត់ប្រាក់រង្វាន់ពីសេវាសាធារណៈមានការយឺតយ៉ាវ និងការរង់ចាំការដាក់មន្ត្រីចូលនិវត្តន៍ជាដើម។ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ៤៦៨ ៧៣៧ លានរៀល ស្មើនឹង ២៩,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ៤,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបានត្រឹមតែ ២៥,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២៣,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។

- ***វិស័យសេដ្ឋកិច្ច*** អនុវត្តបានចំនួន ២៨៦ ៤២១ លានរៀល ស្មើនឹង ២១,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ០,៣% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២១,៦% នៃច្បាប់ហិរញ្ញវត្ថុ, ប៉ុន្តែបើគិតចំណាយជាសាច់ប្រាក់កើនឡើង ១៤,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ក្នុងនោះ **ចំណាយបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ១៤២ ៥៣៣ លានរៀល ស្មើនឹង ៣៤,០% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាង ០,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបានរហូតដល់ ៣៣,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២០,៥% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ជារួម ការបើកផ្តល់ប្រាក់បៀវត្សដំណើរការបានល្អ និងទាន់ពេលវេលា ប៉ុន្តែចំណាយបន្ទុកបុគ្គលិកនេះនៅទាប ដោយសារក្រសួង-ស្ថាប័ននៃវិស័យនេះមានឥណទានធំសម្រាប់ទូទាត់ប្រាក់រង្វាន់ពីសេវាសាធារណៈ ហើយមិនទាន់បានរួសរាន់ធ្វើការទូទាត់នៅក្នុងឆមាសទី ១ នេះ។ **ចំណាយមិនមែនបន្ទុកបុគ្គលិក** អនុវត្តបានចំនួន ១៤៣ ៨៨៨ លានរៀល ស្មើនឹង ១៦,២% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាង ០,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ១៦,៤% នៃច្បាប់ហិរញ្ញវត្ថុ។ ដូចវិស័យដទៃទៀតដែរ ចំណាយក្រៅបន្ទុកបុគ្គលិកនៅឆមាសទី ១ ទាប ដោយសារកិច្ចសន្យាទំនិញ និងសេវាភាគច្រើននឹងត្រូវទូទាត់នៅឆមាសទី ២ ប៉ុន្តែលក្ខណៈដោយឡែកនៃវិស័យនេះ ឥណទានថវិកាសម្រាប់ការជួសជុល និងថែទាំផ្លូវថ្នល់, ស្ពាន, ប្រព័ន្ធធារាសាស្ត្រ ជាទូទៅអនុវត្តយឺតនៅក្នុងឆមាសទី ១ ហើយចំណាយមួយចំនួនលើកិច្ចការនេះ ជាបុរេប្រទានដែលត្រូវទូទាត់នៅក្នុងឆមាសទី ២។

*ជារួមឃើញថា បើធៀបនឹងច្បាប់ហិរញ្ញវត្ថុប្រចាំឆ្នាំ ការអនុវត្តចំណាយនៃគ្រប់វិស័យនៅក្នុងរយៈពេល ៦ ខែដើមឆ្នាំ ២០១៧ សុទ្ធតែមានសន្ទុះលឿនជាងរយៈពេលដូចគ្នានៃឆ្នាំ ២០១៦។*

**ខ.២.១.៤ ចំណាយមូលធន** សរុបសម្រាប់ឆមាសទី ១ ឆ្នាំ ២០១៧ តាមអាណត្តិបើកប្រាក់អនុវត្តបាន ២៣,៤% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាងចំនួន ៥,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២៨,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់ថយចុះ ៣,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ លទ្ធផលនៃការអនុវត្តនេះ រួមមាន **ចំណាយវិនិយោគដោយហិរញ្ញប្បទានក្នុងប្រទេស**អនុវត្តបានចំនួន ២២៤ ៩០៨ លានរៀល ស្មើនឹង ១៥,៨% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាងចំនួន ៤,៧% បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២០,៥% នៃច្បាប់ហិរញ្ញវត្ថុ។ ក៏ប៉ុន្តែបើគិតទាំងបុរេប្រទានចំណាយមូលធន អនុវត្តបានដល់ ៣២,៥% នៃច្បាប់ហិរញ្ញវត្ថុ

គឺមានល្បឿនលឿនជាងចំនួន ៤,១% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២៨,៤% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៣៤,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ ដោយឡែក **ចំណាយមូលនិធិទ្រទ្រង់ថវិកា** អនុវត្តបានចំនួន ២៧ ៤៦៧ លានរៀល ស្មើនឹង ១១,០% នៃច្បាប់ហិរញ្ញវត្ថុ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ **ចំណាយលើការទូទាត់ប្រាក់ខ្ចី** អនុវត្តបានចំនួន ២១៣ ៣៤៦ លានរៀល ស្មើនឹង ៣២,១% នៃច្បាប់ហិរញ្ញវត្ថុ បើធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ គឺមានកំណើន ៧,១%។ **តាមការព្យាករណ៍រហូតដល់ចុងឆ្នាំ ចំណាយមូលធននឹងអាចសម្រេចបានតាមច្បាប់ហិរញ្ញវត្ថុ ឬទាបជាងច្បាប់បន្តិចបន្តួច។**

ខ-២-២ ចំណាយថ្នាក់ក្រោមជាតិ

**ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ** ក្នុងឆមាសទី ១ ឆ្នាំ ២០១៧ អនុវត្តបានចំនួន ៤៧៦ ២១៤ លានរៀល ស្មើនឹង ២៩,៧% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ២,០% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ២៧,៧% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ២៨,៨% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ក្នុងនោះ**ចំណាយចរន្ត** អនុវត្តបានចំនួន ៤២៨ ៨៣៨ លានរៀល ស្មើនឹង ៣០,៩% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនលឿនជាងចំនួន ០,៤% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៣០,៥% នៃច្បាប់ហិរញ្ញវត្ថុ, បើគិតចំណាយជាសាច់ប្រាក់កើនឡើង ១៨,៩% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ (បន្ទុកបុគ្គលិក អនុវត្តបានចំនួន ១៥៤ ៤៦៩ លានរៀល ស្មើនឹង ៤៦,៨% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណាយជាសាច់ប្រាក់កើនឡើង ១០,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦) និង**ចំណាយមូលធន** អនុវត្តបានចំនួន ៤៧ ៣៧៦ លានរៀល ស្មើនឹង ២១,៦% នៃច្បាប់ហិរញ្ញវត្ថុ គឺមានល្បឿនយឺតជាងចំនួន ១៥,៦% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦ ដែលអនុវត្តបាន ៦,០% នៃច្បាប់ហិរញ្ញវត្ថុ បើគិតចំណាយជាសាច់ប្រាក់កើនឡើង ៤១៤,២% ធៀបនឹងរយៈពេលដូចគ្នាក្នុងឆ្នាំ ២០១៦។ **តាមការព្យាករណ៍រហូតដល់ចុងឆ្នាំ ចំណាយថវិការបស់រដ្ឋបាលថ្នាក់ក្រោមជាតិ គឺអាចសម្រេចបានតាមច្បាប់ហិរញ្ញវត្ថុដែលបានកំណត់។**

## ខ-៣ តុល្យភាពចំណូល-ចំណាយ

ជារួមឃើញថា ការអនុវត្តចំណូលថវិកាថ្នាក់ជាតិឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិឆមាសទី ១ ឆ្នាំ ២០១៧ មានលក្ខណៈល្អប្រសើរជាងការអនុវត្តក្នុងឆ្នាំ ២០១៦ គឺសម្រេចបាន ៥៦,៤% នៃច្បាប់ហិរញ្ញវត្ថុ។ ចំពោះផ្នែកចំណាយអនុវត្តបានប្រសើរជាងឆ្នាំ ២០១៦ គឺសម្រេចបាន ៣៩,៥% (គិតទាំងបុរេប្រទាន) នៃច្បាប់ហិរញ្ញវត្ថុ។ ដូចនេះ ជាលទ្ធផលរួមនៃការអនុវត្តថវិកាថ្នាក់ជាតិឆ្លងកាត់អគ្គនាយកដ្ឋានរតនាគារជាតិប្រចាំឆមាសទី ១ ឆ្នាំ ២០១៧ មានអតិរេកជាបណ្ដោះអាសន្នរហូតដល់ប្រមាណ ២ ៤០០ ៤១៧ លានរៀល។ ច្បាស់ណាស់ អតិរេកនេះនឹងធ្លាក់ចុះមកវិញនាចុងឆ្នាំ ក្នុងរង្វង់ប្រមាណ ៨២៣ ៨៩០ លានរៀល នៅពេលគ្រប់ក្រសួង-ស្ថាប័នបង្កើនល្បឿននៃការអនុវត្តចំណាយនៅឆមាសទី ២ នេះ។

## ខ-៤ ហិរញ្ញប្បទានសហប្រតិបត្តិការ

ខ.៤.១ ការដកសាច់ប្រាក់

ច្បាប់ហិរញ្ញវត្ថុឆ្នាំ ២០១៧ គ្រោងទឹកប្រាក់វិនិយោគដោយហិរញ្ញប្បទានក្រៅប្រទេសផ្ទាល់ចំនួន

៤ ២៨៤ ៥៥៧ លានរៀល។ ជាក់ស្តែង ការដកសាច់ប្រាក់យកមកប្រើប្រាស់ក្នុងគម្រោង/កម្មវិធីអភិវឌ្ឍន៍ នៅក្នុងឆមាសទី ១ ឆ្នាំ ២០១៧ ក្នុងក្របខណ្ឌនៃកិច្ចព្រមព្រៀងឥណទានសម្បទាន និងកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង តាមបរិបទរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រេចបានចំនួនសរុបប្រមាណ ៣១១,៣០ លានដុល្លារអាមេរិក ស្មើនឹងចំនួនប្រមាណ ១ ២៣៤ ៤១៦ លានរៀល គឺស្មើនឹងប្រមាណ ២៨,៦% នៃច្បាប់ហិរញ្ញវត្ថុ ហើយក្នុងនោះ៖ ឥណទានសម្បទានសម្រេចបានចំនួន ២៨៦,៣១ លានដុល្លារអាមេរិក គឺស្មើនឹងប្រមាណ ៣១,៧% នៃឥណទានប្រចាំឆ្នាំ និងហិរញ្ញប្បទានឥតសំណងសម្រេចបានចំនួន ១៥,៧៩ លានដុល្លារអាមេរិក គឺស្មើនឹងប្រមាណ ១០,៨% នៃឥណទានប្រចាំឆ្នាំ។ ទឹកប្រាក់នេះមិនទាន់រាប់បញ្ចូលនៅឡើយទេនូវទឹកប្រាក់ហិរញ្ញប្បទានឥតសំណងមួយចំនួនទៀត ដែលត្រូវបានផ្តល់ទៅដល់គោលដៅអនុវត្តផ្ទាល់ដោយដៃគូអភិវឌ្ឍតែម្តង ដោយមិនឆ្លងតាមបរិបទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយរួមទាំងគម្រោងវិនិយោគផ្ទាល់ក្នុងវិស័យហេដ្ឋារចនាសម្ព័ន្ធរូបវ័ន្ត និងសង្គម និងគម្រោងកសាងសមត្ថភាពផងដែរ។

#### ខ.៤.២ ការចុះកិច្ចព្រមព្រៀងថ្មី

ក្នុងឆមាសទី ១ ឆ្នាំ ២០១៧ រាជរដ្ឋាភិបាលបានចុះកិច្ចព្រមព្រៀងហិរញ្ញប្បទានឥតសំណង និងឥណទានសម្បទាន មានទឹកប្រាក់សរុបចំនួនប្រមាណ ៩៩០,៦៦ លានដុល្លារអាមេរិក សម្រាប់អនុវត្ត ១៩ គម្រោង/កម្មវិធីអភិវឌ្ឍន៍ ដែលក្នុងនោះមាន៖

- ហិរញ្ញប្បទានឥតសំណងចំនួន ៧ គម្រោង/កម្មវិធី មានទឹកប្រាក់សរុបចំនួនប្រមាណ ២៥៨,៦០ លានដុល្លារអាមេរិក។ ទឹកប្រាក់នេះមិនរាប់បញ្ចូលទឹកប្រាក់ហិរញ្ញប្បទាន ដែលដៃគូអភិវឌ្ឍន៍បានផ្តល់ទៅដល់បណ្តាគោលដៅអនុវត្តដោយផ្ទាល់ដោយមិនឆ្លងកាត់រាជរដ្ឋាភិបាលទេ។

- ឥណទានសម្បទានចំនួន ១១ គម្រោង មានទឹកប្រាក់សរុបចំនួនប្រមាណ ៧៣២,០៦ លានដុល្លារអាមេរិក គឺស្មើនឹងប្រមាណ ៧៤% នៃច្បាប់ហិរញ្ញវត្ថុ។

## ៣. លទ្ធផលប៉ាន់ស្មាននៃការអនុវត្តថវិកាឆ្នាំ ២០១៧

ផ្អែកលើស្ថានភាពម៉ាក្រូសេដ្ឋកិច្ច និងការអនុវត្តថវិកាពាក់កណ្តាលឆ្នាំ ២០១៧, លទ្ធផលនៃការអនុវត្តថវិកាសម្រាប់ឆ្នាំ ២០១៧ ត្រូវបានប៉ាន់ស្មានដូចខាងក្រោម៖

### ក-ស្ថានភាពចំណូល

ផ្អែកលើលទ្ធផលសម្រេចបានក្នុងឆមាសទី ១ និងនិន្នាការប្រមូលចំណូលឆមាសទី ២ ខាងមុខនេះ អាចសន្និដ្ឋានបានថា ការអនុវត្តចំណូលក្នុងប្រទេសឆ្នាំ ២០១៧ អាចនឹងសម្រេចបានលើសច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ចំនួនប្រមាណ ៤,២% ដោយក្នុងនោះ៖

• ចំណូលចរន្តអាចនឹងអនុវត្តសម្រេចបានលើសច្បាប់ហិរញ្ញវត្ថុប្រមាណ ៣,៧% ដោយសារចំណូលសារពើពន្ធអាចនឹងសម្រេចបានលើសច្បាប់ហិរញ្ញវត្ថុប្រមាណ ៤,១% ចំណែកឯចំណូលមិនមែនសារពើពន្ធអាចនឹងសម្រេចបានខ្ពស់ជាងច្បាប់ហិរញ្ញវត្ថុប្រមាណ ១,០%។

• ចំណូលមូលធនត្រូវបានប៉ាន់ស្មានថានឹងអាចអនុវត្តបានចំនួន ៩៩២ ២៥២ លានរៀល គឺលើសច្បាប់ហិរញ្ញវត្ថុ ចំនួនប្រមាណ ២៣,៥%។

**ខ-ស្ថានភាពចំណាយ**

ជាមួយនឹងការលើកកម្ពស់ប្រសិទ្ធភាពនៃការគ្រប់គ្រងមន្ត្រីរាជការ **ចំណាយបន្ទុកបុគ្គលិក** ត្រូវបានប៉ាន់ស្មានថានឹងអនុវត្តស្មើច្បាប់ហិរញ្ញវត្ថុ ហើយអាចឆ្លើយតបបានទៅនឹងគោលនយោបាយបៀវត្សឆ្នាំ ២០១៧ របស់រាជរដ្ឋាភិបាល មានជាអាទិ៍ (១)-ការដំឡើងប្រាក់បៀវត្សមូលដ្ឋានប្រចាំខែ និងប្រាក់បំណាច់មុខងារជូនមន្ត្រីរាជការស៊ីវិល និងកងកម្លាំងប្រដាប់អាវុធ, តាមផែនការដែលបានគ្រោងទុក, ជាក់ស្តែងបៀវត្សអប្បបរមារបស់មន្ត្រីរាជការបានកើនពី ៧០០ ៥០០ រៀល នៅឆ្នាំ ២០១៦ ដល់ ៨៥៣ ៥០០ រៀល នៅឆ្នាំ ២០១៧ ហើយបៀវត្សអប្បបរមារបស់គ្រូបង្រៀន និង គ្រូពេទ្យបានឡើងពី ៨០០ ៥០០ រៀល ដល់ ៩៥៣ ៥០០ រៀល; (២)- ការដំឡើងរបបសន្តិសុខសង្គមជូនដល់អតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជន ចំនួនប្រមាណ ៤២ ៨១៩ លានរៀល ដើម្បីដំឡើងសោធនទាបបំផុតដល់ ៤២០ ០០០រៀល; (៣)-ការផ្តល់ប្រាក់ឧបត្ថម្ភក្នុងឱកាសពិធីចូលឆ្នាំថ្មីប្រពៃណីជាតិ ឆ្នាំរកា ពុទ្ធសករាជ ២៥៦០ គ.ស ២០១៧ ស្មើៗគ្នាទាំងមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនម្នាក់ចំនួន ៥០ ០០០ រៀល និងក្នុងឱកាសបុណ្យភ្ជុំបិណ្ឌ ឆ្នាំរកា នព្វស័ក ពុទ្ធសករាជ ២៥៦១ គ.ស ២០១៧ ស្មើៗគ្នាទាំងមន្ត្រីរាជការនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ព្រមទាំងអតីតមន្ត្រីរាជការស៊ីវិល និងអតីតយុទ្ធជនម្នាក់ចំនួន ៥០ ០០០ រៀលផងដែរ។

ចំណែកឯ**ចំណាយមិនមែនបន្ទុកបុគ្គលិក** របស់ក្រសួង-ស្ថាប័ន ក្នុងឆមាសទី ២ ខាងមុខ អាចនឹងមានល្បឿនលឿនជាងនៅក្នុងឆមាសទី ១ ព្រោះក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បាននិងកំពុងដាក់ចេញវិធានការចាំបាច់ផ្សេងៗ ដើម្បីជំរុញការអនុវត្តចំណាយនៅឆមាសទី ២ នេះ រួមមាន៖

- បន្តពិនិត្យកែសម្រួលនីតិវិធីបន្ថែមតាមការចាំបាច់ ដើម្បីផ្តល់កិច្ចសម្រួលខាងនីតិវិធីផង ព្រមទាំងដើម្បីលើកកម្ពស់ប្រសិទ្ធភាព និងការទទួលខុសត្រូវក្នុងការអនុវត្តថវិកាផង,
- ទន្ទឹមនឹងការផ្តល់សិទ្ធិអំណាចដល់ក្រសួង-ស្ថាប័នថវិកាកម្មវិធី គឺត្រូវបង្កើនឱ្យមានការទទួល-ខុសត្រូវក្នុងការអនុវត្តកាន់តែច្រើន,
- បន្តពង្រឹងប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈផ្តល់ការបណ្តុះបណ្តាលដល់មន្ត្រីអង្គភាពថវិកានៃក្រសួង-ស្ថាប័នទាំងនៅរដ្ឋបាលកណ្តាល ទាំងមន្ទីរជំនាញរាជធានី ខេត្ត, ពង្រឹងសមត្ថភាពមន្ត្រីបន្ថែមទៀត ដើម្បីត្រៀមដោះស្រាយបញ្ហាផ្នែកបច្ចេកទេសនៃការអនុវត្តប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (FMIS), និងជួបពិភាក្សាឱ្យបានជាប្រចាំជាមួយក្រសួង-ស្ថាប័នពាក់ព័ន្ធ ដើម្បីដោះស្រាយបញ្ហាប្រឈមឱ្យបានទាន់ពេលវេលា ស្របតាមសភាពការណ៍ជាក់ស្តែង។

ជារួម ផ្អែកលើលទ្ធផលអនុវត្តក្នុងឆមាសទី ១ និងនិន្នាការចំណាយឆមាសទី ២ អាចសន្និដ្ឋានបានថាការអនុវត្តចំណាយឆ្នាំ ២០១៧ នឹងមិនលើសច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ ទេ គឺស្ថិតក្នុងរង្វង់ប្រមាណ ៩៨,៤%។ ជាមួយគ្នានេះ ការគណនា និងព្យាករណ៍លើការអនុវត្តចំណូល និងចំណាយខាងលើបង្ហាញឱ្យឃើញថា ការអនុវត្តថវិកាឆ្នាំ ២០១៧ អាចនឹងសម្រេចបានតាមគោលដៅដែលបានកំណត់នៅក្នុងច្បាប់ស្តីពីហិរញ្ញវត្ថុសម្រាប់ការគ្រប់គ្រងឆ្នាំ ២០១៧ **ហើយអាចមានអតិរេកថវិកាប្រមាណ ៨២៣ ៨៩០ លានរៀល។**

## ៤. សេចក្តីសន្និដ្ឋាន

ការអនុវត្តថវិកាឆមាសទី ១ ឆ្នាំ ២០១៧ បានឆ្លុះបញ្ចាំងអំពីលទ្ធផល និងប្រសិទ្ធភាពនៃការកៀរគរចំណូល តាមរយៈការអនុវត្តវិធានការយ៉ាងម៉ឺងម៉ាត់និងមុតស្រួច, ទាំងតាមវិធានការរដ្ឋបាល និងវិធានការគោលនយោបាយ, ជាពិសេស ការលើកកម្ពស់វប្បធម៌បង់ពន្ធ, ការបង្ក្រាបអំពើរត់ពន្ធនិងការគេចវេសពន្ធគ្រប់រូបភាពឱ្យដល់ឫសគល់ និងការកែលម្អអភិបាលកិច្ចក្នុងការប្រមូលចំណូល ព្រមទាំងប្រសិទ្ធភាពនៃប្រតិបត្តិការចំណាយ តាមរយៈការតម្រង់ការចាយឱ្យចំមុខ និងមិនខ្ជះខ្ជាយ ដែលធ្វើឱ្យរាជរដ្ឋាភិបាលមានលទ្ធភាពឆ្លើយតបបានកាន់តែមានប្រសិទ្ធភាពទៅនឹងបណ្តាតម្រូវការជាអាទិភាពនានា ជាពិសេស ការអនុវត្តក្របខណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈឆ្នាំ ២០១៧ ដែលត្រូវបានរៀបចំឡើងស្របតាមអាទិភាពគោលនយោបាយនៃ**វិស័យអាទិភាពទាំង ៤** ដូចមានចែងនៅក្នុង **យុទ្ធសាស្ត្រចតុកោណ-ដំណាក់កាលទី ៣** និង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ ២០១៤-២០១៨**។

ដូចនេះ ថវិកាឆ្នាំ ២០១៧ អាចចាត់ទុកថា ពិតជាកំពុងដើរតួជាឧបករណ៍គោលនយោបាយដ៏មានប្រសិទ្ធភាពសម្រាប់ឆ្លើយតបទៅនឹងបំណងប្រាថ្នារបស់ប្រជាពលរដ្ឋ។ ទន្ទឹមនឹងនេះ ថវិកាឆ្នាំ ២០១៧ ក៏បានដើរតួនាទីយ៉ាងសំខាន់ផងដែរ ជាឧបករណ៍ដ៏មុតស្រួចរបស់រាជរដ្ឋាភិបាលក្នុងការបន្តរក្សាស្ថិរភាពនយោបាយ សន្តិសុខ និងសណ្តាប់ធ្នាប់សង្គម, បន្តពង្រឹងនិងពង្រីកការអនុវត្តលទ្ធិប្រជាធិបតេយ្យ, បន្តរក្សាឱ្យបាននូវស្ថិរភាពម៉ាក្រូសេដ្ឋកិច្ច ដែលជាលក្ខខណ្ឌចាំបាច់មិនអាចខ្វះបានក្នុងការសម្រេចបាននូវគោលដៅជាសារវ័ន្តនៃការទ្រទ្រង់កំណើនសេដ្ឋកិច្ច, ការកាត់បន្ថយភាពក្រីក្រ និងភាពសុខដុមនៃសង្គមជាតិយើងទាំងមូលសម្រាប់រយៈពេលវែង។

សេចក្តីដូចបានគោរពរាយការណ៍ជូនខាងលើ សូម **សម្តេចប្រធានរដ្ឋសភា** មេត្តាជ្រាបជារបាយ-ការណ៍ដ៏ខ្ពង់ខ្ពស់ និងសូមមេត្តាចែកជូនសមាជិក-សមាជិការដ្ឋសភា ដើម្បីជ្រាបជាព័ត៌មានតាមការគួរ។

សូម **សម្តេចអគ្គមហាពញាចក្រី ហេង សំរិន** ប្រធានរដ្ឋសភា មេត្តាទទួលនូវគារវកិច្ចដ៏ខ្ពង់ខ្ពស់បំផុតពីខ្ញុំ

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**បណ្ឌិតសភាចារ្យ អូន ព័ន្ធមុនីរ័ត្ន**

**ចម្លងជូន**

-សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន**
នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

-ឯកសារ-កាលប្បវត្តិ